

## សូមភ្ជាប់ហ្វេសប៊ុកនិងធ្វីតធ័រជាមួយអង្គការ ហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស

### ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការបណ្តុះបណ្តាលកម្មសិក្សាបច្ចេកទេស

អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេសនឹងផ្តល់ព័ត៌មានដល់សិក្ខាកាមតាមហ្វេសប៊ុកនិងធ្វីតធឺ។ខ្លឹមសាររួមមានព័ត៌មានស្តីពីប្រព័ន្ធបណ្តុះបណ្តាលកម្មសិក្សាបច្ចេកទេសក៏ដូចជាវិធានការការពារនានាទាក់ទងនឹងការឆ្លងនៃវីរុសកូរ៉ូណាថ្មី។

### សរសេរជាភាសាជប៉ុនងាយៗស្រួលៗបកប្រែជា៨ភាសាសម្រាប់សិក្ខាកាម

អត្ថបទត្រូវបានសរសេរជាភាសាជប៉ុនងាយៗនិងបកប្រែទៅជា៨ភាសា(ខ្មែរ・វៀតណាម・ចិន・ហ្វីលីពីន・ឥណ្ឌូនេស៊ី・ថៃ・ភូមា・អង់គ្លេស)។អ្នកអាចអានព័ត៌មានថ្មីៗជាភាសាកំណើតដូច្នេះសូមភ្ជាប់ទាំងអស់គ្នា។

Facebook

Twitter



## អាចប្រើប្រាស់សម្រាប់ដាក់ពាក្យជាពលករជំនាញ១បាន! ការធ្វើតេស្តមូលដ្ឋានគ្រឹះ ភាសាជប៉ុនJFT- អាចប្រឡងនៅប្រទេសជប៉ុនបាន!

### អាចយកទៅដាក់ពាក្យជាពលករជំនាញ១បាន!

ការធ្វើតេស្តមូលដ្ឋានគ្រឹះភាសាជប៉ុន "JFT-Basic" ដែលមានតែនៅក្រៅប្រទេសនឹងចាប់ផ្តើមការប្រឡងនៅប្រទេសជប៉ុនចាប់ពីខែមីនានេះហើយ។

ការធ្វើតេស្តនេះដើម្បីវាស់ស្ទង់សមត្ថភាពដែលមានកម្រិតប្រហាក់ប្រហែលនឹងJLPT N4ឬខ្ពស់ជាងនេះដែលអាចប្រើប្រាស់ក្នុងការស្នើសុំទិដ្ឋាការពលករជំនាញបាន។វាជាឱកាសថ្មីមួយដែលអាចធ្វើអោយអ្នកដែរចង់បន្តការស្នាក់នៅក្នុងប្រទេសជប៉ុនក្នុងគោលបំណងរស់នៅនិងធ្វើការបន្ត។

### ក្នុងមួយឆ្នាំ៦ដងទូទាំងខេត្តក្រុងក្នុងប្រទេសជប៉ុនប្រហែល១២០កន្លែង

ការធ្វើតេស្តនេះត្រូវបានគ្រោងធ្វើ៦ដងក្នុងមួយឆ្នាំនៅក្នុងទីក្រុងប្រហែល១២០ទូទាំងប្រទេស។

ការធ្វើតេស្តនេះគឺគ្រាន់តែឆ្លើយសំណួរដោយប្រើកុំព្យូទ័រនៅទីកន្លែងប្រឡង។ថ្លៃប្រឡងគឺ៧,០០០យ៉េន (បូកពន្ធ)។

អ្នកអាចដាក់ពាក្យតាមអ៊ីនធឺណេតបាន។

https://www.jpf.go.jp/jft-basic/index.html

## វិធានការការពារកូរ៉ូណាថ្មីអាចយកមកប្រើប្រាស់លើការការពារការអាឡែរហ្សីលំអងផ្កាបាន!



នៅរដូវផ្ការីកនេះអ្នកដែលមានការអាឡែរហ្សីលំអងផ្កាគួរប្រយ័ត្នចំពោះការឆ្លងមេរោគកូរ៉ូណាផងដែរ។ប្រសិនបើអ្នកប៉ះមុខរបស់អ្នកឬត្រដុសភ្នែកឬច្រមុះអ្នកនឹងប្រឈមនឹងការឆ្លងមេរោគ។

លំអងមិនមែនជាវីរុសទេដូច្នេះត្រូវគិតលើវិធានការមួយចំនួនដើម្បីប្រឆាំងការពារដូចនឹងការការពារមេរោគកូរ៉ូណាផងដែរ។

### លាងជម្រះលំអងជាមួយទឹក

លំអងផ្កាមិនអាចជ្រុះដោយសារការបាញ់ទឹកសម្លាប់មេរោគនោះទេ។លាងដៃជាមួយសាប៊ូដើម្បីលាងជម្រះលំអងផ្កាចេញ។

### ពាក់ម៉ាស២ជាន់

ការពាក់ម៉ាសមិនកាត់លំអងទាំងស្រុងទេ។វាក៏មានប្រសិទ្ធភាពផងដែរបើសិនយើងពាក់ម៉ាស២ជាន់។

### អាការៈកណ្តាស់

មនុស្សមួយចំនួនមានការព្រួយបារម្ភលើការកណ្តាស់ដោយអាឡែរហ្សីជាមួយលំអងផ្កាដោយខ្លាចថាជាការកណ្តាស់ដោយកើតជម្ងឺកូរ៉ូណា។នៅពេលអ្នកកណ្តាស់ព្យាយាមយកកន្សែងដៃខ្ទប់ឬអោនមុខចុះក្រោម។

### ពាក់វ៉ែនតា

ដើម្បីការពារកុំឲប៉ះពាល់ភ្នែកគឺការពាក់វ៉ែនតា។មិនចាំបាច់ត្រូវពាក់វ៉ែនតាការពារមេរោគនោះទេវ៉ែនតាធម្មតាក៏បានដែរ។

### ដាក់វាំងននៅលើបង្អួច

ការបើកបង្អួចដើម្បីឲខ្យល់ចេញចូលដើម្បីការពារកូរ៉ូណានោះលំអងនឹងចូលមកផងដែរ។ប្រសិនបើបើកបង្អួចប្រហែល10សង់ទីម៉ែត្រហើយភ្ជាប់វាំងននបាំងនោះអាចកាត់បន្ថយលំអងបានមួយភាគបួនផងដែរ។

## បទសម្ភាសន៍ជាមួយបេក្ខជនជាប់ការប្រលងសមត្ថភាពភាសាជប៉ុន (JLPT)





[ជាប់ក្នុងសម័យប្រឡងនៅខែ១២ឆ្នាំ២០២០]

**លោកស្វាយចាន់រតនា**

(ក្រុមហ៊ុនសំណង់អេអូអេស / សំណង់ការពារទឹកជ្រាប)

--តើលោកមានវិធីសាស្ត្រអ្វីក្នុងការសិក្សា?

នៅពេលដែរបញ្ចប់ពីការងាររាល់ថ្ងៃខ្ញុំតែងតែចំនាយពេលរៀនពី១០នាទីទៅ២០នាទីជារៀងរាល់យប់។

[ការអាន]បន្ថែមពីលើការសិក្សាសៀវភៅJLPTខ្ញុំបានអានសៀវភៅស្តីពីរបៀបរស់នៅនិងវប្បធម៌របស់ជនជាតិជប៉ុន។ដូច្នេះខ្ញុំគិតថាការអាននិងសិក្សាអ្វីក៏ដោយសៀវភៅណាមួយក៏ដោយសុទ្ធតែមានប្រយោជន៍ដែរ។

[ការស្តាប់]ខ្ញុំតែងតែព្យាយាមស្តាប់ការសន្ទនាជាភាសាជប៉ុនរបស់ជនជាតិនិងស្តាប់ចម្រៀងជប៉ុន។

[ការសន្ទនា]ខ្ញុំបានព្យាយាមនិយាយជាមួយជនជាតិជប៉ុនហើយពេលខ្លះក៏បានសម្តែងជាតួរសន្ទនាម្នាក់ឯងផងដែរ។

--តើមានអ្វីទៀតដែលលោកយល់ថាមានប្រយោជន៍ទៅដល់ការសិក្សារបស់លោក?

ការមើលរឿងតុក្កតាជប៉ុននិងភាពយន្តជប៉ុន។

--ការប្រឡងN3ចំនួន២ដងមកហើយ។តើអ្វីដែលជម្រុញអោយលោកនៅតែបន្តការខិតខំរៀនសូត្រ?

ការរៀនបណ្តើរធ្វើការបណ្តើរវាពិតជាពិបាកណាស់។ប៉ុន្តែវាជាឳកាសល្អមួយដែលអាចសិក្សាគ្រប់យ៉ាងក្នុងអំឡុងពេលរស់នៅប្រទេសជប៉ុន។

--តើគោលដៅអនាគតយ៉ាងមិចដែរ?

ខ្ញុំកំពុងខិតខំរៀនដើម្បីយកN2។បន្ទាប់ពីត្រឡប់ពីប្រទេសជប៉ុនវិញខ្ញុំនឹងអាចបង្កើនសមត្ថភាពភាសានិងចង់ធ្វើការងារប្រើប្រាស់ភាសាជប៉ុនផងដែរ។

-- ពាក្យផ្តែផ្តាំទៅកាន់មិត្តសិក្ខាកាម

ខ្ញុំគិតថារាល់ថ្ងៃការធ្វើការផងរៀនផងវាពិតជាលំបាកណាស់ប៉ុន្តែវាល្អសម្រាប់យើងគ្រប់គ្នាដូច្នេះសូមកុំភ្លេចការសិក្សា។ ចូលធ្វើឱ្យអស់ពីសមត្ថភាព។

「やる気」 "ឆន្ទៈឬការលើកទឹកចិត្ត"

「根気」 "ការតស៊ូឬការអត់ធ្មត់"

「元気」 " ថាមពលឬសុខភាពល្អ"។